ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២១១៩ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៦

## សេចក្តីជូនដំណឹង
## អំពីកម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីជាដុល្លារឆ្នាំ២០១៥

អនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា១៨ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី២.៥ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និង យោងតាមសេចក្តីណែនាំអំពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស លេខ១៥១ អពដ. ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារបានកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីជាប្រាក់ដុល្លារ ឆ្នាំ២០១៥ ចំនួន ១០.២៨ % ក្នុងមួយឆ្នាំ។ អត្រាការប្រាក់នេះ បានមកពីការគណនាមធ្យមភាគ នៃមធ្យមភាគអត្រាការប្រាក់ឲ្យខ្ចីរបស់ធនាគារពាណិជ្ជធំៗ ក្នុងស្រុកចំនួន ០៩ (ប្រាំបួន)។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវអនុវត្តតាមខ្លឹមសារ នៃសេចក្តីជូនដំណឹងនេះ ចំពោះលទ្ធផលសារពើពន្ធសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៥ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល